# សេចក្តីថ្លែងការណ៍រួម

# របស់អង្គការសង្គមស៊ីវិលនាឱកាសទិវាជនចំណាកស្រុកអន្តរជាតិលើកទី១៩

# ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

ស្របពេលដែលបណ្តាប្រទេសជាច្រើននៅលើពិភពលោក បាននឹងកំពុងប្រារព្ធ **ទិវាជនចំណាកស្រុកអន្តរជាតិ ១៨ ធ្នូ** ប្រទេសកម្ពុជាក៏បានប្រារព្ធពិធីនេះ ដើម្បីចូលរួមជាមួយ នឹងបណ្តាប្រទេសនានានៅលើពិភពលោក ក្នុងការជំរុញអោយមានការលើកស្ទួយ និងការគោរពនូវសិទ្ធិជាមូលដ្ឋានរបស់ជនចំណាកស្រុកកម្ពុជាផងដែរ ។

**ទិវាជនចំណាកស្រុកអន្តរជាតិលើកទី១៩នេះ** នឹងត្រូវបានអង្គការសង្គមស៊ីវិលប្រារព្ធនាទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៩ នេះផងដែរ។ ទិវានេះធ្វើឡើងក្នុងគោលបំណង:

*១. ដើម្បីចូលរួមអបអរសាទរទិវាជនចំណាកស្រុកអន្តរជាតិ ១៨ ធ្នូ លើកទី៤ នៅព្រះរាជាណាចក្រកម្ពុជា ដែលផ្តួចផ្តើមរៀបចំឡើងដោយអង្គការខារ៉ាមកម្ពុជា និងជាខួបលើកទី១៩ របស់ពិភពលោក ដែលទទួលស្គាល់នូវការចូលរួមចំណែករបស់ពលករក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច និងវប្បធម៌ របស់ប្រទេសទទួល និងបញ្ជូន បន្ទាប់ពីមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិ ពលករចំណាកស្រុក និងសមាជិកគ្រួសាររបស់គេនៅឆ្នាំ១៩៩០ ។*

*២. ទាក់ទាញការគាំទ្រពីអ្នកធ្វើសេចក្តីសំរេចចិត្ត អ្នកធ្វើគោលនយោបាយ និងភាគីពាក់ព័ន្ធនានា ចំពោះបញ្ហាចំណាកស្រុក ដើម្បីអោយមានការពិនិត្យមើលឡើងវិញ និងបង្កើតគោលនយោបាយ បទបញ្ញត្តិ និងច្បាប់នានាដែលពាក់ព័ន្ធ ដើម្បីលើកកំពស់ និងការពារសិទ្ធិពលករចំណាកស្រុក ។*

*៣. ដើម្បីបង្កើនការយល់ដឹងជាសាធារណៈស្តីពីសុវត្ថិភាពចំណាកស្រុក ក្នុងបរិយាកាសមួយដែលអាចធ្វើទៅបាន និងពង្រឹងសិទ្ធិអំណាចជនចំណាកស្រុក ក្នុងការកាត់បន្ថយផលប៉ះពាល់ និងភាពងាយរងគ្រោះផ្សេងៗរបស់ពលករចំណាកស្រុក ។*

ទន្ទឹមពេលនឹងការអបអរសាទរទិវាជនចំណាកស្រុកអន្តរជាតិលើកទី១៩ ឆ្នាំនេះ អង្គការសង្គមស៊ីវិលកម្ពុជា ក៏សូមសំដែងនូវក្តីបារម្ភចំពោះបញ្ហាមួយចំនួន ដែលតែងតែកើតឡើងចំពោះជនចំណាកស្រុក ដែលក្នុងនោះរួមមានដូចជា:

- **មុនពេលចាកចេញពីប្រទេសកំណើតៈ**

នៅមុនពេលចេញដំណើរពីប្រទេសកំណើត ពលករចំណាកស្រុកតែងតែរងនូវការរំលោភសិទ្ធិ និងការកេងប្រវ័ញ្ច ជាច្រើនរូបភាព ដូចជា ការទាមទារអោយបង់ប្រាក់ច្រើនហួសហេតុទៅលើការរៀបចំឯកសារ និងលិខិតឆ្លងដែន ការបង្ខំអោយរស់នៅក្នុងស្ថានភាពមិនសមរម្យ កង្វះការតាមដានស្ថានភាពនៅកន្លែងការងារ ការព្រងើយកន្តើយចំពោះ ការតវ៉ា និងការកាត់ប្រាក់ឈ្នួល មិនមានការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់ ការធ្វើតេស្តឈាមដោយបង្ខំរក មេរោគអេសដ៏ព្រមទាំង មិនមានកិច្ចសន្យាការងារដែលមានបទដ្ឋានងាយស្រួល និងត្រឹមត្រូវ ។

- **ក្រោយពេលទៅដល់ប្រទេសទទួលៈ**

នៅក្រោយពេលទៅដល់ប្រទេសទទួល ពលករចំណាកស្រុករងនូវការរំលោភបំពានដោយនិយោជកនៅប្រទេស ទទួលដោយត្រូវបានគេ បង្ខំអោយធ្វើការច្រើនម៉ោង សំរាកតិចតួច ឬមិនបានសំរាក ម្ហូបអាហារមិនសមស្រប ការរំលោភបំពានលើរាងកាយ និងការកេងប្រវ័ញ្ច រឹតត្បិតសេរីភាពក្នុងការដើរហើរនិងប្រាស្រ័យទាក់ទង ។ លើសពីនេះ ពួកគេក៏ប្រឈមមុខនឹងការរើសអើងអំពី គោលនយោបាយ វប្បធម៌ និងទំនៀមទំលាប់នៃប្រទេសទទួល ឬក៏ត្រូវប្រឈម ដកលិខិតឆ្លងដែន និងឯកសារផ្សេងៗ ។ ម្យ៉ាងវិញទៀត ការងារតាមផ្ទះដែលធ្វើដោយពលករចំណាកស្រុក មិនបានត្រូវគ្រប ដណ្តប់ដោយច្បាប់ការងារនៃប្រទេសទទួលភាគច្រើននោះទេ។

- **ការធ្វើសមាហរណកម្មមកប្រទេសកំណើតៈ**

នៅក្រោយពេលធ្វើសមាហរណកម្មមកប្រទេសកំណើតវិញ ពលករខ្លះមានផ្ទុកមេរោគអេដស៍ ឬជំងឺកាមរោគ ផ្សេងៗ និងមានផ្ទៃពោះ ដែលជាហេតុធ្វើឱ្យគេត្រូវបានរើសអើងនៅក្នុងសហគមន៍ និងមិនមានគោលនយោបាយ លើកទឹកចិត្តក្នុងការសងបំណុលដែលពលករបានជំពាក់។

ដូចនេះ ឆ្លៀតក្នុងឱកាសនៃការប្រារព្ធទិវាជនចំណាកស្រុកអន្តរជាតិសំរាប់ព្រះរាជាណាចក្រកម្ពុជា **លើកទី៤** យើងខ្ញុំជា អង្គការសង្គមស៊ីវិល សូមធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមដោះស្រាយ និងការពារនូវសិទ្ធិរបស់ពលករចំណាកស្រុក ដូចខាងក្រោមៈ

- គួរតែធ្វើវិសោធនកម្មអោយបានប្រសើរជាងមុននូវអនុក្រឹតលេខ៥៧ ស្តីពីការគ្រប់គ្រង និង ការបញ្ជូនពលករកម្ពុជា ទៅធ្វើការនៅបរទេស ដែលត្រូវបានប្រកាសអោយប្រើប្រាស់តាំងពីឆ្នាំ១៩៩៥ ព្រោះ បទបញ្ញត្តិជាច្រើន នៅក្នុងនោះ មានភាពមិនច្បាស់លាស់ និងមិនស្របទៅតាមតម្រូវការបច្ចុប្បន្នក្នុងកិច្ចការពារ ប្រកបដោយ ប្រសិទ្ធិភាពនូវសិទ្ធិរបស់ពលករចំណាកស្រុក។

- គួររៀបចំអោយមានជាបទដ្ឋាន កិច្ចសន្យាការងារដែលមានចែងយ៉ាងជាក់លាក់ អំពីសិទ្ធិជាមូលដ្ឋានរបស់ពលករចំណាកស្រុក ព្រមទាំងរៀបចំយន្តការសំរាប់ការពារសិទ្ធិទាំងនោះ។ នៅក្នុងកិច្ចសន្យាការងារ ក៏ត្រូវចែងយ៉ាងច្បាស់លាស់ និងលំអិតអំពីបទពិពណ៌នាការងារ ក៏ដូចជាពត៌មានទាក់ទងទៅនឹងលក្ខខណ្ឌការងារ និងការរស់នៅដែលពលករនឹងជួបប្រទះ នៅប្រទេសទទួល។
- ផ្តល់ជូននូវព័ត៌មានចាំបាច់ និងឱកាសសំរាប់ប្រើប្រាស់សេវាធ្វើតេស្តឈាមដោយស្ម័គ្រចិត្តដល់ពលករចំណាកស្រុក ក៏ដូចជាផ្តល់ឱកាសទទួលបានសេវាផ្តល់ប្រឹក្សា និងការព្យាបាលផ្អែកតាមលទ្ធផលជាក់ស្តែងនៃការធ្វើតេស្ត។
- រៀបចំអនុស្សារណៈនៃការយោគយល់គ្នា (MoU) ជាមួយបណ្តាប្រទេសដែលទទួលពលករចំណាកស្រុកកម្ពុជា ដោយត្រូវពិគ្រោះយោបល់ជាមួយនឹងអង្គការសង្គមស៊ីវិលជំនាញផងដែរ នៅគ្រប់ដំណើរការនេះ។ អនុស្សារណៈនេះគួរមានខ្លឹមសាររួមស្របនឹង អនុសញ្ញាអន្តរជាតិស្តីពី ការពារសិទ្ធិពលករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេ រួមមាន កិច្ចធានាឱ្យមានភាពត្រឹមត្រូវចំពោះប្រាក់បៀវត្ស លក្ខខណ្ឌការងារផ្សេងទៀត សេវាថែទាំសុខភាព ព្រមទាំងសិទ្ធិប្តឹងអំពីទុក្ខលំបាករបស់ខ្លួនទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអោយមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នៅក្នុងប្រទេសទទួលនោះផងដែរ។
- គួរពង្រឹងយន្តការតាមដានក្រុមហ៊ុនជ្រើសរើសពលករ និងចាត់វិធានតាមផ្លូវច្បាប់តឹងរ៉ឹងចំពោះ ករណីមិនប្រក្រតីណាមួយប្រព្រឹត្តឡើងដោយក្រុមហ៊ុន និងចាត់វិធានការណ៍ដ៏សមរម្យណាមួយចំពោះសាលាបង្រៀនភាសាកូរ៉េ ដែលផ្សព្វផ្សាយពាណិជកម្មបំភ័ន្តធ្វើអោយពលករ ឬសាធារណជនយល់ច្រលំថា ជាភ្នាក់ងារបញ្ជូនពលករទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ។
- គួរធ្វើវិសោធនកម្មច្បាប់ការងារដោយដាក់បញ្ចូលអ្នកធ្វើការងារតាមផ្ទះ ដើម្បីឱ្យមានសិទ្ធិ និងឱកាស ស្របទៅតាមបទដ្ឋានច្បាប់អន្តរជាតិ។
- គួរតែបង្កើតការងារឱ្យបានច្រើនទាក់ទិននឹងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ទេសចរណ៍ និងសំណង់ ជាដើម ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ច ជាជាងការយកប្រាក់ដែលពលករធ្វើការនៅបរទេសសំរាប់ជាឧបករណ៍ជួយជំរុញកំណើន សេដ្ឋកិច្ចជាតិ ដែលមិនមែនជាការអភិវឌ្ឍន៍រយៈពេលវែង ដែលមាននិរន្តភាពនោះទេ។

***សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:***


| | | |
|---|---|---|
| **លោក យ៉ា ណាវុធ** | នាយកប្រតិបត្តិអង្គការខារ៉ាមកម្ពុជា/ប្រធានស្តីទី NGO CEDAW | លេខ: ០១២ ៩៦១ ៤២៧ |
| **លោក ហង្ស ឆាយា** | ប្រធានសម្របសម្រួល CHRAC/នាយកប្រតិបត្តិ KID | លេខ: ០១២ ៨៦៩ ៩១០ |
| **លោក ហង្ស ពុទ្ធា** | នាយកប្រតិបត្តិអង្គការ NICFEC | លេខ: ០១២ ៩៥៩ ៦៦៦ |
| **លោក ធន សារាយ** | ប្រធានសមាគមអាដហុក | លេខ: ០១៦ ៨៨០ ៥០៩ |
| **លោក សុក សំអឿន** | នាយកប្រតិបត្តិ CDP | លេខ: ០១២ ៩០១ ១៩៩ |